| 91 | *Hypoperigea leprosticta* | INS | Noctuidae | Lepidoptera | Durian Fruit Borer | Durian |
| 92 | *Hypothenemus hampei* (ferrari) | INS | Scolytidae | Coleoptera | Coffee berry bore | |
| 93 | *Iceria purchasi* | INS | Margarodidae | Homoptera | Ladybird beetle | Orange |
| 94 | *Icerya aegyptiaca* | INS | Margarodidae | Hemiptera | Bread fruit mealbug | Mango |
| 95 | *Icerya pulchra* | INS | Margarodidae | Homoptera | Magarodid Scales | Durian |
| 96 | *Idiocerus atkinsoni* | INS | Cicadellidae | Homoptera | Mango leaf hopper | Mango |
| 97 | *Idiocerus clypealis* | INS | Cicadellidae | Homoptera | Mango leaf hopper | Mango |
| 98 | *Lepidosaphes gloverii* | INS | Diaspididae | Homoptera | Glover scale | Orange |
| 99 | *Leptinotarsa decemlineata* say | INS | Crysomelidae | Coleoptera | Collorado beetle | Potato |
| 100 | *Lolium temulentum* | WEE | Poacea | Cyperales | Ryegrass | Rice, Potato |
| 101 | *Lopholencaspis japonica* | INS | Diaspididae | Hemiptera | Japanese beton shaped scale | Orange |
| 102 | *Maconellicoccus hirsutus* | INS | Pseudococcidae | Hemiptera | Grapevine mealy bug | Mango |
| 103 | *Macrophoma mantegazziana* | FUN | Sphaeropsidaceae | Sphaerosidales | - | Orange |
| 104 | *Marasmiellus scandens* | INS | Marasmiaceae | Agaricales | White Thread Blight | Durian |
| 105 | *Marumba dyras* | INS | Sphingidae | Lepidoptera | Hawk Moths | Durian |
| 106 | *Melolontha melolontha L.* | INS | Scarabaeidae | Coleoptera | White grub cockchafer | Potato |
| 107 | *Monalonion* | INS | Miridae | Hemiptera | Banana Sting Bug | Banana |
| 108 | *Morganella longispina* | INS | Diaspididae | Hemiptera | Plumose scal | Mango |
| 109 | *Mudaria magniplaga* | INS | Noctuidae | Lepidoptera | Fruit Borer | Durian |

| | | | | | | |
|---|---|---|---|---|---|---|
| 110 | *Mycosphaerella fijensis* | FUN | Mycosphaerellaceae | Mycosphaerellales | Black Sigatoka | Banana |
| 111 | *Mycosphaerella musae* | FUN | Mycosphaerellaceae | Mycosphaerellales | Speckle Disease | Banana |
| 112 | *Nacoleia ostasema* | INS | Pyralidae | Lepidoptera | Banana Scab Moth | Banana |
| 113 | *Nectria rigidiuscula* | INS | Nectriaceae | Hypocreales | Cushion Gall Disease | Durian |
| 114 | *Nipaecoccus viridis* | INS | Pseudococcidae | Hemiptera | Spherical meal bug | Mango |
| 115 | *Nisotra javanica* | INS | Chrysomelidae | Coleoptera | Leaf Beetles | Durian |
| 116 | *Oospora pustulans* Owen et Wakef | FUN | Moniliaceae | Moniliales | Powdery scab | Potato |
| 117 | *Opogona sacchari* | INS | Tineidae | Lepidoptera | Banana Moth | Banana |
| 118 | *Orgyia turbata* | INS | Lymantriidae | Lepidoptera | Tussock Moth | Durian |
| 119 | *Orgyuia postica* | INS | Lymantriidae | Lepidoptera | Small tussock mont | Orchid |
| 120 | *Orobanche aegyptiaca* | WEE | Orobanchaceae | Scrophulariales | Egyptian broomrape | Potato |
| 121 | *Orobanche cernua* | WEE | Orobanchaceae | Scrophulariales | Broomrape | Potato |
| 122 | *Orobanche ramosa* | WEE | Orobanchaceae | Scrophulariales | Bean broomrape | Potato |
| 123 | *Oryzaephilus mercator* (Fauvel) | INS | Silvanidae | Coleoptera | Merchant grain beetle | Rice |
| 124 | *Oxyodes scrobiculata* | INS | Noctuidae | Lepidoptera | Leaf Eating, Looper | Durian |
| 125 | *Pachymerus cardo* (Fabricius) | INS | Bruchidae | Coleoptera | Kernel borer | |
| 126 | *Pachymerus lacerdae* (Cheverlot) | INS | Bruchidae | Coleoptera | Kernel borer | |
| 127 | *Pachymerus nucleorum* (Fabricius) | INS | Bruchidae | Coleoptera | Kernel borer | |
| 128 | *Panonychus ulmi* | ACA | Tetranychidae | Acarina | Eropean red mite | Mango |
| 129 | *Penicillum digitarum* | FUN | Moniliaceae | Moniliales | Green mould | Orange |
| 130 | *Phoma andina* Turk | FUN | Sphanopsidacae | Sphanopsidales | Phoma leaf spot | Potato |
| 131 | *Phoma solaniacola* Pill et Del | FUN | Sphanopsidacae | Sphanopsidales | Leaf bloth | Potato |
| 132 | *Phomopsis citri* | FUN | Valsaceae | Diaporthales | Citrus melanose | Orange |
| 133 | *Phthorimaea operculella* | INS | Gelechidae | Lepidoptera | Potato moth | Potato |
| 134 | *Phymatotrichopsis omnivora* (Duggar) Hennebert | FUN | | Hyphomicetales | Texas root rot of cotton. | |
| 135 | *Phymatotrichum omnivorum* | FUN | Scrophulariaceae | Scrophulariales | Cotton root rot | Potato |
| 136 | *Planococcus citri* | INS | Pseudococcidae | Hemiptera | Citrus mealy bug | Mango |
| 137 | *Planococcus lilacinus* | INS | Pseudococcidae | Hemiptera | Coffee mealy bug | Mango |
| 138 | *Pomacea sp.* | MOL | Ampullariidae | Architaenioglossa | Golden Apple Snail | |
| 139 | *Pratylenchus gooddeyi* | NEM | Pratylenchidae | - | Banana Lesion Nematode | Banana |
| 140 | *Prostephanus truncatus* | INS | Brostrichidae | Coleoptera | Large grain borer | Rice |
| 141 | *Pseudococcus elisae* Borchsenius | INS | Pseudococcidae | Hemiptera | Banana Mealy Bug | Banana |
| 142 | *Pseudococus gahani* | INS | Pseudococcidae | Homoptera | Citrus mealy bug | Orange |
| 143 | *Pseudococus maritimus* | INS | Pseudococcidae | Homoptera | Mealy bug | Orange |
| 144 | *Pseudomonas garcae* | FUN | Pseudomonadaceae | Pseudomonadales | Coffe arabica | Potato |
| 145 | *Pseudomonas solanacearum* | BAC | Ralsotoniaceae | Burkholderiales | Bacterial Wilt | Banana |
| 146 | *Pseudomonas solanacearum pv.celebensis* | BAC | Ralsotoniaceae | Burkholderiales | Banana Blood Disease | Banana |
| 147 | *Pseudotheraptus wayi* | INS | Coreidae | Hemiptera | Coconut bug | Mango |
| 148 | *Pulvinaria psidii* | INS | Coccididae | Hemiptera | Guava mealy scale | Mango |
| 149 | *Radionaspis indica* | INS | - | Hemiptera | Mealy bugs | Mango |
| 150 | *Radopholus similis* | NEM | Pratylenchidae | Tylenchida | Burrowing nematode | Mango, Orchid, Banana |
| 151 | *Rastrococcus iceryoides* | INS | Pseudococcidae | Homoptera | Downey Snow Line mealy Bug | Durian |
| 152 | *Rhizopus spp.* | FUN | Mucoraceae | Mucorales | Moulding of stored seedling | Orange |
| 153 | *Rice hoja blanca virus* | VIR | Unassigned virus | Tenuivirus | Chlorosis of rice. | Rice |
| 154 | *Saissetia coffeae* | INS | Coccididae | Hemiptera | Brown scale | Mango |
| 155 | *Scirtothrips citri* | INS | Tripidae | Tysanoptera | Thrips | Orange |
| 156 | *Selenotrips rubrocinctus* | INS | Tripidae | Tysanoptera | Red banded trip | Mango |
| 157 | *Septoria lycopersici speg* | FUN | Sphanopsidacae | Sphanopsidales | Septoria blight | Potato |
| 158 | *Septoria spp* | FUN | Sphaeropsidaceae | Sphaerosidales | Septoria spot | Orange |
| 159 | *Sitophilus granarius* | INS | Dryophthoridae | Coleoptera | Granary weevil | Rice |
| 160 | *Spiroplasma citri* | FUN | Spiroplasmataceae | Entomoplasmatales | Stubborn disease | Orange |
| 161 | *Spongospora subterranea* | FUN | Plasmodiophoraceae | Plasmodiophorales | Powdery scab | Potato |
| 162 | *Sternochetus mangiferae* | INS | Cucurlionidae | Coleoptera | Mango seed weevil | Mango |
| 163 | *Stethopachus formosa* | INS | - | Coleoptera | Dendridium beetles | Orchid |
| 164 | *Striga augustifolia* | WEE | Scrophulariaceae | Dicotylodonae | Witchweed | Rice |
| 165 | *Striga densiflora* | WEE | Scrophulariaceae | Scrophulariales | Benth | Rice |
| 166 | *Striga hermothica* | WEE | Scrophulariaceae | Scrophulariales | Witchweed | Rice |
| 167 | *Striga lutae* | WEE | Scrophulariaceae | Scrophulariales | Vining weed | Rice |
| 168 | *Synchytrium endobioticum* | FUN | Synchytriaceae | Chytridiales | Potato wart disease | Potato |
| 169 | *Tagosodes cubanus* D. L. Crawford | INS | Delphacidae | Hemiptera | Paddy plant hopper | Rice |
| 170 | *Tagosodes orizicolus Muir* | INS | Delphacidae | Hemiptera | Rice delphacid | Rice |

| | | | | | | |
|---|---|---|---|---|---|---|
| 171 | *Tetranychus urticae* | ACA | Tetranychidae | Acari | Red spider mite | Orchid |
| 172 | *Thrips hawaiiensis* | INS | Thripidae | Thysanoptera | Flower Thrip | Banana |
| 173 | *Toxoptera citricidus* | INS | Aphididae | Hemiptera | Citrus brown aphid | Orange |
| 174 | *Trachysphaera fructigena* | INS | Pyralidae | Pythiales | Ciga End Rot of Banana | Banana |
| 175 | *Tribolium confusum* Duval | INS | Tenebrionidae | Coleoptera | Flour weevil | Rice |
| 176 | *Trioza erytreae* | INS | Triozidae | Hemiptera | Africa citruspsylla | Orange |
| 177 | *Trogoderma granarium* | INS | Dermistidae | Coleoptera | Khapra beetle | Rice |
| 178 | *Trogoderma inclusum* | INS | Dermistidae | Coleoptera | Large cabinet beetle | Rice |
| 179 | *Ustilago maydis* (Beckm) Unger | FUN | Ustilaginaceae | Ustilaginales | Corn smut. | |
| 180 | *Verticilium albo-atrumr* | FUN | Moniliaceae | Moniliales | Verticillium disease | Potato |
| 181 | *Verticillium albo-atrum* Reincke & Berth | FUN | Moniliaceaa | Moniliales | Wilt | |
| 182 | *Whetzelinia sclerotiorum* Korf et Dumont | FUN | Sclerotiaceae | Helotiales | Colla rot | Potato |
| 183 | *Xyleborus apertus* | INS | Scolytidae | Coleoptera | Stunk Borer | Durian |
| 184 | *Xyloxandrus compactus* | INS | Scolytidae | Coleoptera | Short-hold borer | Orchid |

**កំណត់សំគាល់** (Note):

**ACA** : Acarina (ពពួកក្រុមចៃ ឬស្រមើល)

**BAC** : Bacteria (ពពួកបាក់តេរី)

**FUN** : Fungi (ពពួកក្រុមផ្សិតជាភ្នាក់ងារបង្ករោគ)

**INS** : Insect (ពពួកក្រុមសត្វល្អិត)

**MOL** : Mollusca (ពពួកក្រុមខ្យង)

**NEM** : Nematode (ពពួកក្រុមណេម៉ាតូដ)

**VIR** : Virus (ពពួកក្រុមវីរុសជាភ្នាក់ងារបង្ករោគ)

**WEE** : Weed (ពពួកក្រុមស្មៅចង្រៃ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១៣១ ប្រក កសក

លិខិតចូល
ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ 2010

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពី ការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** ប្រកាសនេះ មានគោលបំណងកំណត់អំពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និងកន្លែងតាំងលក់ សំដៅធានាគុណភាព សុវត្ថិភាពសាច់ និង ផលិតផលសត្វ ដើម្បីរួមចំណែករក្សាបាននូវសុខភាពសាធារណៈ និង សុវត្ថិភាពចំណីអាហារ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ :** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលទទួលសិទ្ធិកាន់កាប់ ឬ ប្រើប្រាស់សត្តឃាតដ្ឋាន ត្រូវអនុវត្តវិធានអនាម័យសត្តឃាតដ្ឋាន ដូចខាងក្រោម ÷

- បង្កភាពងាយស្រួលដល់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យការអនុវត្តនីតិបទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន
- ត្រូវបង្ហាញដល់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច នូវលិខិតអនុញ្ញាតដឹកជញ្ជូនសត្វ វិញ្ញាបនបត្រអនាម័យសត្វ អត្តសញ្ញាណប័ណ្ណសត្វ និង លិខិតបញ្ជាក់សុខភាពរបស់បុគ្គលិក-កម្មករ
- ត្រូវអនុវត្តតាមការណែនាំរបស់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច នៅតាមសត្តឃាតដ្ឋាន អំពីការធ្វើអនាម័យសត្តឃាតដ្ឋាន
- ត្រូវបោស លាងសម្អាត និង សម្លាប់មេរោគ នៅកន្លែងទុកសត្វសម្រាករង់ចាំការពិឃាត ឱ្យបានជាប្រចាំរាល់ពេលបញ្ចេញសត្វអស់
- ត្រូវធ្វើអនាម័យកន្លែងពិឃាត ដោយចាប់ផ្តើមប្រមូលកាកសំណល់ផ្សេងៗ និងកម្ទេចកម្ទីទាំងឡាយដូចជា: រោម ស្នែង ក្រចក ស្បែក ខ្លាញ់ កម្ទេចកម្ទីល្អិតៗនៃសាច់ ចេញពីកម្រាលបរិវេណពិឃាត ទើបដុសលាងសម្អាតធ្វើ ជញ្ជាំង និង កម្រាលក្រោម ដោយប្រើប្រាស់ជាមួយសាប៊ូ ឬ ជាមួយសារធាតុសម្រាប់លាងសម្អាត បន្ទាប់មកត្រូវអនុវត្តនូវវិធានអនាម័យ ដោយលាងសម្អាតជាមួយនឹងទឹកក្តៅដែលមានសីតុណ្ហភាពយ៉ាងទាបបំផុត ៨២អង្សាសេ

- ត្រូវអនុវត្តវិធានអនាម័យលើឧបករណ៍ សម្ភារៈ ប្រើប្រាស់ផ្ទាល់ជាមួយសត្វ និង សាច់ ដោយត្រាំក្នុងធុងទឹកក្តៅ ដែលមានសីតុណ្ហភាពយ៉ាងទាបបំផុត ៨២អង្សាសេ ដើម្បីសម្លាប់មេរោគ និង ត្រូវឧស្សាហ៍ផ្លាស់ប្តូរទឹកឱ្យបានញឹកញាប់ ។

**ប្រការ ៣ :** ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ នៅសត្តឃាតដ្ឋាន ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

**ក- ការត្រួតពិនិត្យសត្វរស់មុនពេលពិឃាត**

- ត្រូវត្រួតពិនិត្យលិខិតអនុញ្ញាតដឹកជញ្ជូនសត្វ វិញ្ញាបនបត្រអនាម័យសត្វ អត្តសញ្ញាណប័ណ្ណសត្វ ឬ ភិនសត្វ
- ត្រូវពិនិត្យការរក្សាទុកសត្វនៅកន្លែងបង្ខាំងសត្វ ក្នុងសត្តឃាតដ្ឋានរយៈពេលពី ១២(ដប់ពីរ)ម៉ោង ទៅ២៤(ម្ភៃបួន)ម៉ោង មុនធ្វើការពិឃាត
- ត្រូវពិនិត្យសុខភាពសត្វ ពិនិត្យអាការៈខាងក្រៅសត្វ ដូចជា: ពិនិត្យស្បែក រោម វាស់កំដៅ ជំហរ អាកប្បកិរិយា សង្វាក់ដង្ហើម ច្រមុះ ភ្នែក ភ្នាសសើម ប្រដាប់រំលាយអាហារ ប្រដាប់បន្តពូជ ។ល។ ករណីសង្ស័យ ត្រូវបញ្ជូនវត្ថុវិភាគទៅមន្ទីរពិសោធន៍ ដើម្បីធ្វើរោគវិនិច្ឆ័យ
- ត្រូវពិនិត្យការរក្សាទុកឱ្យនៅដាច់ឡែកពីសត្វដទៃ ចំពោះសត្វដែលសង្ស័យមានជំងឺ ដោយរង់ចាំលទ្ធផលវិភាគ
- ត្រូវហាមឃាត់ការពិឃាតសត្វដែលសង្ស័យមានជំងឺ និង សត្វឈឺ ។ ចំពោះសត្វដែលនៅសង្ស័យថាឈឺ សត្វឈឺ និង សត្វស្លាប់ ត្រូវអនុវត្តវិធានបសុពេទ្យតាមការចាំបាច់ ។

**ខ- ការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ ក្រោយពេលពិឃាត**

- ត្រូវធ្វើការពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ ក្រោយពេលពិឃាត តាមលក្ខណៈប្រព័ន្ធដើម្បីធានាថាសាច់ និង ផលិតផលសត្វទាំងនោះ មានអនាម័យ និង មានសុវត្ថិភាពសម្រាប់យកទៅបរិភោគ
- ត្រូវធ្វើការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ ភ្លាមក្រោយពេលពិឃាត
- ត្រូវបិទស្លាកលើកញ្ចប់សាច់ ឬ ផលិតផលបក្សី និង ត្រូវបង់លេខសម្គាល់ ក្បាល សរីរាង្គ គ្រឿងក្នុង ផ្ទាំងសាច់ និង ផ្នែកផ្សេងៗទៀតនៃផ្ទាំងសាច់ ដែលត្រូវធ្វើការត្រួតពិនិត្យអនាម័យ ជៀសវាងការច្រឡំ
- ត្រូវធ្វើការពិនិត្យក្រពេញទឹករងៃ និង គីស្តនៅលើសាច់ផ្ទាល់ អណ្តាតរបស់ គោ ក្របី ជ្រូក និង សត្វចិញ្ចឹមដទៃទៀត

- ត្រូវដាក់នៅដោយឡែក ដើម្បីធ្វើការពិនិត្យលម្អិតបន្ថែមទៀតនូវកញ្ចប់សាច់ និង ផលិតផលសត្វ ផ្ទាំងសាច់ ឬ ផ្នែកណាមួយនៃសរីរាង្គ គ្រឿងក្នុង ដែលសង្ស័យថាមិនអាចបរិភោគបាន
- ហាមច្រៀវ កាត់ចេញ ឬ កែច្នៃបំបាត់ស្លាកស្នាម ភស្តុតាងនៃជំងឺ ដែលមាននៅលើផ្ទាំងសាច់ សរីរាង្គ គ្រឿងក្នុង ឬ ភ្នាសស៊េរ៉ូម នៅមុនពេលត្រួតពិនិត្យអនាម័យ
- ត្រូវហាមយកឈាម ផ្នែកណាមួយនៃផ្ទាំងសាច់ សរីរាង្គ ឬ គ្រឿងក្នុង ចេញពីកន្លែងពិឃាតដោយពុំបានឆ្លងកាត់ការត្រួតពិនិត្យ។

លទ្ធផលនៃការត្រួតពិនិត្យ និង ការសម្រេចចុងក្រោយ លើការអនុញ្ញាតឱ្យយកទៅបរិភោគបាន ឬ យកទៅកែច្នៃ គឺជាភារ កិច្ចទទួលខុសត្រូវរបស់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច។

ក្រោយពិនិត្យឃើញថា សាច់ និង ផលិតផលសត្វ មានអនាម័យ មានគុណភាព និង មានសុវត្ថិភាព ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចត្រូវបោះត្រា ឬ អូសត្រាលើផ្ទាំងសាច់ ឬ បិទស្លាកសម្គាល់បសុពេទ្យលើកញ្ចប់សាច់ ផលិតផលសត្វ និង ចេញវិញ្ញាបនបត្របញ្ជាក់អនាម័យ។

**ប្រការ ៤ :** ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចត្រូវអនុវត្ត នីតិវិធីនៃការត្រួតពិនិត្យអនាម័យ សាច់ និង ផលិតផលសត្វ នៅកន្លែងតាំងលក់ដូចខាងក្រោម ÷

- ត្រួតពិនិត្យវិញ្ញាបនបត្របញ្ជាក់អនាម័យសាច់ និង ផលិតផលសត្វ
- ពិនិត្យត្រា និង ស្លាកសម្គាល់លើផ្ទាំងសាច់ កញ្ចប់សាច់ ឬ កញ្ចប់ផលិតផលសត្វ
- ត្រួតពិនិត្យអនាម័យកន្លែងតាំងលក់សាច់ និង ផលិតផលសត្វ
- ត្រួតពិនិត្យអនាម័យ គុណភាពសាច់ និង ផលិតផលសត្វ ពណ៌ ក្លិន ឬ ភាពរូស និង ភាពមិនប្រក្រតីដទៃទៀត។

**ប្រការ ៥ :** ការត្រួតពិនិត្យអនាម័យ សាច់ និង ផលិតផលសត្វ តាមប្រភេទជំងឺនីមួយៗ ត្រូវកំណត់ក្នុងសារាចរណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រភេទជំងឺសត្វ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ មានចែងក្នុងប្រកាសលេខ ០១៤ ប្រក.កសក. ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦ ស្តីពី បញ្ជីរាយឈ្មោះជំងឺឆ្លងរាតត្បាតសត្វ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ប្រភេទជំងឺសត្វសំខាន់ៗ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ នៅក្នុងសត្តឃាតដ្ឋាន មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ការកំណត់កំរិតនៃវត្ថុមានសុវត្ថិភាពមេរោគ ការកំណត់កំរិតកាកសំណល់អតិបរិមានៃសារធាតុគីមី និង វត្ថុមានអ័រមូនហាមឃាត់ក្នុងសាច់ និង ផលិតផលសត្វ ត្រូវកំណត់នៅក្នុងប្រកាសដោយឡែក របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**ប្រការ ៦ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧ ៖** អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល គ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្ម និង ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី.០៨...ខែ.[illegible]..ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ នាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ភ្ជាប់ប្រកាសលេខ.១៣១...ប្រក.កសក
ចុះថ្ងៃទី.០៩......ខែ.ឧសភា.......ឆ្នាំ ២០១០

# បញ្ជីរាយឈ្មោះជំងឺសំខាន់ៗ ដែលជាកម្មវត្ថុនៃ ការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ

| | |
|---|---|
| **១- ជំងឺឆ្លង** | |
| - ជំងឺឈាមខ្មៅ | Anthrax |
| - ជំងឺអុតក្តាម | Foot and Mouth Disease |
| - ជំងឺសាទឹក | Pasteurellosis/Haemorrhagic Septicemia |
| - ជំងឺប្រ៊ុយសែលឡូស | Brucellosis |
| - ជំងឺតេតាណូស | Tetanus |
| - ជំងឺរបេង | Tuberculosis |
| - ជំងឺគោឆ្កួត | Bovine Spongiform Encephalopathy |
| - ជំងឺបូសខ្យល់ | Black leg |
| - ជំងឺកាំពីឡូបាក់តេរីយ៉ូស | Campilobacter enteritis |
| - ជំងឺប៉េស្ត | Classical Swine Fever/Hog Cholera |
| - ជំងឺកញ្ជ្រិល | Erysipelas |
| - ជំងឺស្ត្រិបតូកុក | Streptococcus infection |
| - ជំងឺសាលម៉ូណែឡា | Salmonellosis |
| **២- ជំងឺបង្កដោយប៉ារ៉ាស៊ីត** | |
| - ជំងឺចុងអង្ករគោ ក្របី | Bovine cysticercosis |
| - ជំងឺចុងអង្ករជ្រូក | Porcine cysticercosis |
| - ជំងឺទ្រីគីន | Trichinellosis |
| - ជំងឺហ្វាស្យូឡា | Fasciolosis |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ២៤៦ ប្រក. កសក

លិខិតចូល

ថ្ងៃទី.០៤...ខែឧសភា..ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់គំរូសៀវភៅបន្ទុកនៃឡូត៍នេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពី ការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពី ការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួល អគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ ស្ដីពី នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានដាក់ឱ្យប្រើប្រាស់គំរូសៀវភៅបន្ទុកសម្រាប់ធ្វើអាជីវកម្មឡូត៍នេសាទទឹកសាបដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២ :** ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានរដ្ឋបាលជលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- សាលារាជធានី ខេត្ត

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និង នេសាទ

រដ្ឋបាលជលផល

លេខ............................ជផ

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០១០
ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសៀវភៅបន្ទុកនៃឡូត៍នេសាទ

# សៀវភៅបន្ទុក

ឡូត៍នេសាទ ............................. លេខ................... រាជធានី/ខេត្ត ...............

សម្រាប់ធ្វើអាជីវកម្មក្នុងរដូវនេសាទឆ្នាំ ២០ .......... ~ ២០ ..............

និង រដូវនេសាទឆ្នាំ ២០ ......... ~ ២០ ...............

ឈ្មោះអ្នកទទួលសិទ្ធិកាន់កាប់ : ...................................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និង នេសាទ

រដ្ឋបាលជលផល

## សៀវភៅបន្ទុក

**ឡូត៍នេសាទ** ................................ **លេខ** .................. **រាជធានី/ខេត្ត** ..........................

សម្រាប់ដាក់ឱ្យធ្វើអាជីវកម្មក្នុងរដូវនេសាទឆ្នាំ ២០ ........- ២០ ......... និងឆ្នាំ ២០ .........- ២០ .............

**ប្រការ ១ :** អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ តាមសេចក្តីសម្រេចលេខ ............. សសរ.កសក ចុះថ្ងៃទី ........ ខែ ............. ឆ្នាំ ២០ ........ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបង់ថ្លៃឈ្នួលឡូត៍នេសាទជូនរដ្ឋចំនួន..........................................នៅរតនាគាររាជធានី ខេត្តសាមី។ ថ្លៃឈ្នួលនេះជាលទ្ធផលនៃការដេញថ្លៃនៅថ្ងៃទី ............. ខែ ............. ឆ្នាំ ២០ ......។

**ប្រការ ២ :** មុនពេលធ្វើអាជីវកម្ម អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទពីរដ្ឋបាលជលផលថ្នាក់កណ្តាល។

**ប្រការ ៣ :** ការបង់ប្រាក់ថ្លៃឈ្នួលឡូត៍នេសាទត្រូវបានកំណត់ជា ........... លើក ក្នុងមួយរដូវនេសាទ ទៅតាមរយៈពេលនៃការធ្វើអាជីវកម្មនេសាទ និងតាមប្រភេទនៃឡូត៍នេសាទនីមួយៗ :

**រដូវទី ១ :**

លើកទី ១ : ថ្ងៃទី ........ ខែ ............ ឆ្នាំ ២០ ......... ចំនួន .............................................. រៀល

លើកទី ២ : ថ្ងៃទី ........ ខែ ............. ឆ្នាំ ២០ ........ ចំនួន .............................................. រៀល

លើកទី ៣ : ថ្ងៃទី ........ ខែ ............. ឆ្នាំ ២០ ........ ចំនួន .............................................. រៀល

**រដូវទី ២ :**

លើកទី ១ : ថ្ងៃទី ........ ខែ ............ ឆ្នាំ ២០ ......... ចំនួន .............................................. រៀល

លើកទី ២ : ថ្ងៃទី ........ ខែ ............ ឆ្នាំ ២០ ......... ចំនួន .............................................. រៀល

លើកទី ៣ : ថ្ងៃទី ........ ខែ ............ ឆ្នាំ ២០ ......... ចំនួន .............................................. រៀល

ការកំណត់ចំនួនប្រាក់ដែលត្រូវបង់នៅចុងរដូវនេសាទទី ២ ត្រូវស្មើនឹងចំនួនប្រាក់កក់ធានាស្ពាព ហើយត្រូវបង្វែរប្រាក់កក់ធានាស្ពាពនេះ សម្រាប់បង់បង្គ្រប់ថ្លៃឈ្នួលឡូត៍នេសាទតែម្តង។

ក្នុងករណីការបង់ប្រាក់មានការយឺតយ៉ាវចាប់ពីមួយខែឡើងទៅ ត្រូវពិន័យក្នុងមួយថ្ងៃ ០,៤% នៃប្រាក់ដែលបង់មិនទាន់នោះ។ បើលើសពី ២ ខែឡើងទៅ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ឯឡូត៍នេសាទត្រូវដកហូត ហើយប្រាក់ធានាស្ពាពក៏ត្រូវរឹបអូសតាមផ្លូវច្បាប់ដែរ។

**ប្រការ ៤:** អ្នកដេញថ្លៃបាន ត្រូវមានកាតព្វកិច្ចបង់ពន្ធដារជូនអង្គការពន្ធមូលដ្ឋាននូវ :

- ពន្ធប៉ាតង់
- អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញ ក្នុងអត្រារួម ៥% នៃថ្លៃដេញបាន ដោយបង់ជាចំណែកៗ តាមចំនួនលើក និងពេលវេលាដូចមានកំណត់ក្នុងប្រការ ៣ ខាងលើ ។

**ប្រការ ៥:** អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវ :

១- ថែរក្សា និងការពារព្រៃលិចទឹកនៅក្នុងឡូត៍នេសាទ ។

២- ដាំព្រៃលិចទឹកបន្ថែមនៅកន្លែងសមស្រប ដែលកំណត់ដោយរដ្ឋបាលជលផលមានសមត្ថកិច្ច ។

៣- រៀបចំផ្លូវភ្លើងការពារព្រៃលិចទឹកនៅក្នុងឡូត៍នេសាទតាមការណែនាំរបស់រដ្ឋបាលជលផល ។

៤- ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទនៅក្នុងឡូត៍នេសាទ ដោយសហការជាមួយសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ។

៥- រៀបចំឱ្យមានកន្លែងភ្ញាស់ត្រី កន្លែងអភិរក្សត្រីមេពូជ និងលែងកូនត្រីចំនួន ...............ក្បាល នៅក្នុងឡូត៍នេសាទ ។ ដោយឡែក ចំពោះឡូត៍នេសាទដែលមិនអាចរៀបចំកន្លែងភ្ញាស់ត្រី ឬកន្លែងអភិរក្សត្រីមេពូជបាន ត្រូវរក្សាទុកត្រីមេពូជចំនួន .......................... ដើម្បីលែងក្នុងដែននេសាទ ។

៦- អនុវត្តតាមខ្លឹមសារដែលបានចែងក្នុងសៀវភៅបន្ទុក លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងឡូត៍នេសាទ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

៧- លែងទៅក្នុងដែននេសាទវិញនូវប្រភេទមច្ឆជាតិកំពុងរងគ្រោះថ្នាក់ ។

**ប្រការ ៦:** អ្នកដែលបានទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ មិនអាចយកឡូត៍នេសាទទាំងមូល ឬផ្នែកណាមួយនៃឡូត៍នេសាទដែលបានទទួលសិទ្ធិកាន់កាប់ ទៅជួលឱ្យអ្នកដទៃឡើយ ។ ក្នុងករណីមានការរំលោភបទប្បញ្ញត្តិនេះ ត្រូវនិរាករណ៍សិទ្ធិនៃការកាន់កាប់ឡូត៍នេសាទនោះ ។

**ប្រការ ៧:** អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទគ្មានសិទ្ធិទាមទារឱ្យរដ្ឋសងការខូចខាត ឬសុំបន្ថយប្រាក់ថ្លៃឈ្នួលឡូត៍នេសាទ ដែលបណ្តាលមកពីគ្រោះធម្មជាតិ ឬករណីប្រធានសក្តិផ្សេងៗឡើយ ។

**ប្រការ ៨:** ទីកន្លែងសម្រាប់ធ្វើអាជីវកម្មនេសាទ ត្រូវបានកំណត់នៅក្នុងបរិវេណព្រំប្រទល់នៃនាទីឡូត៍នេសាទ លើកលែងតែកន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ និងកន្លែងអភិរក្ស ។

កន្លែងដែលទុកសម្រាប់ប្រជាពលរដ្ឋនៅក្នុងឡូត៍នេសាទ ត្រូវបានកំណត់ដូចខាងក្រោម :

- ទី ១ : ............................................................. ស្ថិតនៅ ....................................
- ទី ២ : ............................................................. ស្ថិតនៅ ....................................
- ទី ៣ : ............................................................. ស្ថិតនៅ ....................................

ស្ង

- ទី ៤ : .................................................................ស្ថិតនៅ.......................................
- ទី ៥ : .................................................................ស្ថិតនៅ .......................................
- ទី ៦ : .................................................................ស្ថិតនៅ .......................................
- ទី ៧ : .................................................................ស្ថិតនៅ .......................................
- ទី ៨ : .................................................................ស្ថិតនៅ .......................................
- ទី ៩ : .................................................................ស្ថិតនៅ .......................................
- ទី ១០ : ...............................................................ស្ថិតនៅ .......................................

កន្លែងអភិរក្ស ត្រូវបានកំណត់ដូចខាងក្រោម :

- ទី ១ : .................................................................ស្ថិតនៅ .......................................
- ទី ២ : .................................................................ស្ថិតនៅ .......................................
- ទី ៣ : .................................................................ស្ថិតនៅ .......................................

ព្រំប្រទល់នៃនាទីឡូត៍នេសាទ កន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ និងកន្លែងអភិរក្ស ត្រូវបានកំណត់យកតាមផែនទី ដែលមានភ្ជាប់មកជាមួយ ។

ចំពោះឡូត៍ដាយ ត្រូវដាក់ឱ្យចំទីតាំងសម្រាប់ធ្វើអាជីវកម្មនេសាទ ដូចបានកំណត់ក្នុងផែនទីដែលមានភ្ជាប់មកជាមួយ ។

**ប្រការ ៩:** មុនពេលធ្វើអាជីវកម្មនេសាទ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវ :

- បោះតម្រុយតាមបង្គោលព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ ហើយដាក់សញ្ញាសំគាល់នៅចុងបង្គោល ។
- ធ្វើស្លាកសញ្ញាសំគាល់ បោះបង្គោល និងមានមធ្យោបាយសម្រាប់ដំណើរការបោះបង្គោលឡូត៍នេសាទ ។
- ថែរក្សា និងជួសជុលឡើងវិញនូវបង្គោលព្រំប្រទល់ឡូត៍នេសាទដែលមានរួចហើយ ។

ការបោះតម្រុយនៅតាមបង្គោលព្រំប្រទល់ឡូត៍នេសាទ ត្រូវមានការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមផែនទីឡូត៍នេសាទពីគណៈកម្មការបោះបង្គោលព្រំប្រទល់ឡូត៍នេសាទ ដែលមានសមាសភាពដូចខាងក្រោម :

១- ប្រធាននាយកដ្ឋានកិច្ចការជលផល ឬតំណាង ជាប្រធាន
២- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង ជាអនុប្រធាន
៣- អភិបាលនៃគណៈអភិបាលក្រុងខណ្ឌ ឬស្រុកដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាអនុប្រធាន
៤- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង ជាសមាជិកអចិន្ត្រៃយ៍
៥- មេឃុំ ឬចៅសង្កាត់ដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក
៦- ប្រធានភូមិដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

៧- ប្រធានគណៈកម្មការសហគមន៍នេសាទដែលឡូត៍នេសាទនៅជាប់ ឬតំណាង ជាសមាជិក

គណៈកម្មការបោះបង្គោលព្រំប្រទល់ឡូត៍នេសាទ ត្រូវធ្វើកំណត់ហេតុនៃការបោះបង្គោលដោយមានអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទចុះហត្ថលេខាឯកភាព។ កំណត់ហេតុនេះ ត្រូវតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌ ឬខណ្ឌរដ្ឋបាលជលផលសាមី អធិការដ្ឋានរដ្ឋបាលជលផលសាមី រដ្ឋបាលជលផលថ្នាក់កណ្តាល និងសហគមន៍នេសាទដែលឡូត៍នេសាទនៅជាប់ ហើយត្រូវបិទផ្សាយជាសាធារណៈ។

កំណត់ហេតុខាងលើត្រូវបញ្ជាក់ ៖

១- និយាមកាទីតាំងបង្គោលនីមួយៗ ដោយបញ្ជាក់បន្ថែមពីមូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ និងសញ្ញាសំគាល់។

២- ចម្ងាយពីបង្គោលនីមួយៗ ទៅចំណុចភូមិសាស្ត្រសំខាន់ៗ។

ក្នុងករណីមិនឯកភាពគ្នាក្នុងការបោះបង្គោល ត្រូវបង្កើតគណៈកម្មការត្រួតពិនិត្យការបោះព្រំប្រទល់ឡូត៍នេសាទ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានរដ្ឋបាលជលផល ឬតំណាង | ជាប្រធាន |
| ២- ប្រធាននាយកដ្ឋានកិច្ចការជលផល ឬតំណាង | ជាអនុប្រធាន |
| ៣- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង | ជាអនុប្រធាន |
| ៤- អភិបាលនៃគណៈអភិបាលក្រុង ខណ្ឌ ឬស្រុកដែលឡូត៍នេសាទនៅជាប់ ឬតំណាង | ជាអនុប្រធាន |
| ៥- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង | ជាសមាជិកអចិន្ត្រៃយ៍ |
| ៦- មេឃុំ ឬចៅសង្កាត់ដែលឡូត៍នេសាទនៅជាប់ ឬតំណាង | ជាសមាជិក |
| ៧- ប្រធានភូមិដែលឡូត៍នេសាទនៅជាប់ ឬតំណាង | ជាសមាជិក |
| ៨- ប្រធានគណៈកម្មការសហគមន៍នេសាទដែលឡូត៍នេសាទនៅជាប់ ឬតំណាង | ជាសមាជិក |

គណៈកម្មការខាងលើនេះ ត្រូវពិនិត្យផ្ទៀងផ្ទាត់តាមផែនទីឡូត៍នេសាទ និងសម្រេចឱ្យបោះបង្គោលតែម្តង។ ក្នុងករណីនេះ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មការ ហើយត្រូវចុះហត្ថលេខាឯកភាពលើកំណត់ហេតុ។

ចំពោះឡូត៍ដាយ មុនពេលធ្វើអាជីវកម្មនេសាទ ក៏ត្រូវមានគណៈកម្មការចូលរួមផ្ទៀងផ្ទាត់កំណត់ទីតាំងដាក់ដាយតាមផែនទីឡូត៍នេសាទ ដែលមានសមាសភាពដូចគណៈកម្មការបោះបង្គោលឡូត៍នេសាទខាងលើ។ ក្នុងករណីមិនឯកភាព ត្រូវបង្កើតគណៈកម្មការ និងអនុវត្តតាមនីតិវិធី ដូចខាងលើដែរ។

**ប្រការ ១០:** ក- រយៈពេលធ្វើអាជីវកម្មនេសាទចាប់ផ្តើមពីថ្ងៃទី ............ ខែ ............... ឆ្នាំ ..................... ដល់ថ្ងៃទី ............. ខែ .................. ឆ្នាំ ..................... ។

ខ- ទីតាំង ប្រភេទ និងទំហំឧបករណ៍នេសាទ ពេលវេលាចាប់ផ្តើម និងបញ្ចប់ការធ្វើអាជីវកម្មនេសាទ និងពេលវេលាដែលត្រូវរុះរើទីតាំងនេសាទ ត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ។

**ប្រការ ១១:** រយៈពេលបើកនេសាទសម្រាប់ធ្វើអាជីវកម្មក្នុងឡូត៍នេសាទគ្រប់ប្រភេទ អាចអនុញ្ញាតក្នុងចន្លោះពេលចាប់ពីថ្ងៃទី ០១ ខែ តុលា ដល់ថ្ងៃទី ០១ ខែ មិថុនា តាមស្ថានភាពភូមិសាស្ត្រនៃឡូត៍នេសាទនីមួយៗ លើកលែងតែឡូត៍ដាយត្រីលិញ ។

មុនរដូវបិទនេសាទយ៉ាងតិច ១៥ ថ្ងៃ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវធ្វើលិខិតស្នើសុំសន្និធិផលនេសាទក្នុងឡូត៍នេសាទនៅខណ្ឌរដ្ឋបាលជលផលសាមី ។

**ប្រការ ១២** : ហាមឃាត់ដាច់ខាតចំពោះការធ្វើអាជីវកម្មឡូត៍នេសាទដូចខាងក្រោម :

១- ធ្វើនេសាទហួសពីព្រំប្រទល់ឡូត៍នេសាទ ឬខុសពីទីតាំងឡូត៍នេសាទ ។

២- ធ្វើនេសាទដោយប្រើមធ្យោបាយផ្សេងៗ ទោះមើលឃើញក្តី មើលមិនឃើញក្តី ដើម្បីចាប់ត្រីពីក្រៅឡូត៍នេសាទ ។

**៣- ធ្វើនេសាទដោយប្រើឧបករណ៍គ្រប់ប្រភេទ ដើម្បីហ៊ុម ឬកៀរជាលើកទីពីរ បន្ទាប់ពីការហ៊ុម ឬកៀរលើកទីមួយម្តងហើយ ចំពោះឡូត៍នេសាទបឹងព្រៃក និងឡូត៍នេសាទប្រើឧបករណ៍ ណ រត់ឈូង នៅក្នុងបឹងទន្លេសាប ។**

**ប្រការ ១៣:** ប្រជាពលរដ្ឋ ដែលមានទីលំនៅក្នុងឡូត៍នេសាទ អ្នកនេសាទជាលក្ខណៈគ្រួសារ ឬសិប្បកម្ម អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវគោរពតាមលក្ខខណ្ឌ ដូចខាងក្រោម :

**ក-** <u>ប្រជាពលរដ្ឋដែលមានទីលំនៅក្នុងឡូត៍នេសាទ</u> :

១- អាចធ្វើដំណើរដឹកជញ្ជូនទំនិញគ្រប់ប្រភេទ ឬផលនេសាទដែលចាប់បានក្រៅពីឡូត៍នេសាទឆ្លងកាត់ចុះឡើងបាន ប៉ុន្តែហាមធ្វើឱ្យរាំងស្ទះដល់ការធ្វើអាជីវកម្មនេសាទ ។

២- អាចប្រើប្រាស់ទឹកសម្រាប់សេចក្តីត្រូវការក្នុងគ្រួសារ ដើម្បីបង្កបង្កើនផលស្រូវ និងដំណាំផ្សេងៗ ប៉ុន្តែហាមបង្ហូរ ឬបិទទឹក ដែលធ្វើឱ្យមានការប្រែប្រួលរបបទឹក និងធ្វើឱ្យខូចដល់ការធ្វើអាជីវកម្មនេសាទក្នុងឡូត៍នេសាទ ។

៣- អាចធ្វើនេសាទក្នុងកន្លែងនេសាទដែលទុកសម្រាប់ប្រជាពលរដ្ឋ ។

**ខ-** <u>អ្នកនេសាទជាលក្ខណៈគ្រួសារ ឬសិប្បកម្ម</u> :

នៅក្នុងរយៈពេលបើកនេសាទនៃឡូត៍នេសាទ ត្រូវហាមឃាត់ការធ្វើនេសាទជាលក្ខណៈគ្រួសារ ឬសិប្បកម្មក្នុងកន្លែងនេសាទបម្រុងត្រង់ចំណុច ដែលមានចំងាយ ២០០ ម៉ែត្រ ពី :

- ព្រំប្រទល់ឡូត៍បឹងព្រៃកផ្នែកខាងមុខច្រកចេញ ចូលចរាចរត្រី ឬផ្នែកខាងបរិវេណដែលប្រើរបាំងព្រួល ។
- មុខឡូត៍ដាយគ្រប់ប្រភេទ ។

**គ-** <u>អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ</u> :

១- ត្រូវគោរពតាមការសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលអនុញ្ញាតតាមសំណើរបស់រដ្ឋបាលជលផលឱ្យប្រជាពលរដ្ឋធ្វើទំនប់ រំលាយទំនប់ ឬជីកប្រឡាយដើម្បីផលប្រយោជន៍ដល់ការបង្កបង្កើនផលស្រូវ ឬដំណាំផ្សេងៗ ។

២- មិនត្រូវសាងសង់លំនៅដ្ឋានជាអចិន្ត្រៃយ៍សម្រាប់បម្រើការធ្វើអាជីវកម្ម ឬសម្រាប់ការរស់នៅរបស់កម្មករ ដែលបម្រើការងារឡូត៍នេសាទ នៅក្នុងឡូត៍នេសាទឡើយ ។

៣- ក្នុងករណីគ្មានសេចក្តីសម្រេចពាក់ព័ន្ធនឹងចំណុច ១ ខាងលើ ហាមធ្វើសកម្មភាពអ្វីទាំងអស់ដែលធ្វើឱ្យមានការប្រែប្រួលរបបទឹក ឬរាំខានដល់ចរាចរនៃជលយានតូចៗ ដែលធ្វើដំណើរឆ្លងកាត់ចុះឡើង និងការធ្វើអាជីវកម្មនេសាទ ។

ក្នុងករណីមានវិវាទរវាងប្រជាពលរដ្ឋ និងអ្នកដែលទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវបង្កើតគណៈកម្មការមួយ ដើម្បីដោះស្រាយទំនាស់ ដែលមានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| ១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង | ជាប្រធាន |
| ២- ប្រធានរដ្ឋបាលជលផល ឬតំណាង | ជាអនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានកិច្ចការជលផល ឬតំណាង | ជាសមាជិក |
| ៤- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង | ជាសមាជិក |
| ៥- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង | ជាសមាជិកអចិន្ត្រៃយ៍ |
| ៦- អភិបាលនៃគណៈអភិបាលក្រុង ខណ្ឌ ឬស្រុកដែលឡូត៍នេសាទនៅជាប់ ឬតំណាង | ជាសមាជិក |
| ៧- មេឃុំ ឬចៅសង្កាត់ដែលឡូត៍នេសាទនៅជាប់ ឬតំណាង | ជាសមាជិក |

ករណីដោះស្រាយមិនបាន ត្រូវធ្វើសំណើមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីសម្រេច ។

**ប្រការ ១៤ :** ក្រៅពីការគោរពឱ្យបានត្រឹមត្រូវតាមបទបញ្ជាទាំងឡាយ ដែលមានចែងក្នុងសៀវភៅបន្ទុកនេះ ឬតាមកិច្ចសន្យា អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវគោរពតាមខ្លឹមសារនៃច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផលថែមទៀត ។

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវទទួលខុសត្រូវចំពោះបទល្មើសជលផល ដែលសាមីខ្លួនសមាជិកក្នុងក្រុម ឬកម្មកររបស់ខ្លួនបាន ឬកំពុងប្រព្រឹត្ត ។

ក្នុងករណីដែលអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ :

- ទទួលមរណភាព ឬបាត់បង់សមត្ថភាព ដោយមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលជលផលត្រូវរៀបចំសំណុំបែបបទដើម្បីផ្ទេរទៅឱ្យសហពទ្ធ ឬកូន ឬតំណាងស្របច្បាប់ទទួលខុសត្រូវជំនួសតាមការស្នើសុំ ។ ក្នុងករណីគ្មានជនណាម្នាក់បានទទួលខុសត្រូវជំនួស ឡូត៍នេសាទទាំងមូលត្រូវដកហូតវិញ ដើម្បីរៀបចំដេញថ្លៃសារជាថ្មី ។ ករណីមិនអាចរៀបចំដេញថ្លៃជាថ្មីបាន អាចជួលតាមការកំណត់របស់សមត្ថកិច្ចរដ្ឋបាលជលផល និងស្នើសុំសេចក្តីសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- បោះបង់ឡូត៍នេសាទចោល ឬមិនគោរពកិច្ចសន្យា និងសៀវភៅបន្ទុក ឡូត៍នេសាទទាំងមូលត្រូវដកហូត និងប្រាក់កក់ធានាស្ពាពត្រូវរឹបអូស ព្រមទាំងបញ្ជូនសំណុំរឿងទៅតុលាការ ដើម្បី

ទាមទារសំណងការខូចខាតពីអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទដែលបានបង្កឡើង ។

- ប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្ទុយនឹងច្បាប់ស្តីពីជលផល ឬលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យជលផល ឡូត៍នេសាទទាំងមូលត្រូវដកហូត និងបញ្ជូនសំណុំរឿងទៅតុលាការដើម្បីចាត់ការតាមនីតិវិធី ។

គ្រប់ករណីខាងលើនេះ បើអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទមិនបង់ប្រាក់ឱ្យគ្រប់ចំនួនតាមការកំណត់ក្នុងសៀវភៅបន្ទុកនេះ ឬតាមកិច្ចសន្យា ឧបករណ៍សម្រាប់ធ្វើនេសាទត្រូវរឹបអូសតាមផ្លូវច្បាប់ដើម្បីលក់ទូទាត់ប្រាក់ឱ្យបានគ្រប់ចំនួន ។ បន្ថែមពីលើនេះទៀត ជនល្មើសត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមានថែមទៀត ។

**ប្រការ ១៥** : សៀវភៅបន្ទុកនេះ មានសុពលភាពអនុវត្តរយៈពេល ២ រដូវនេសាទ គឺស្មើនឹង ១ អាណត្តិនេសាទ ។ ក្នុងករណីឡូត៍នេសាទត្រូវបានដកហូតមុនអាណត្តិនេសាទ សុពលភាពនៃសៀវភៅបន្ទុកនេះក៏ត្រូវបញ្ចប់ស្របតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០ ...

**ប្រធានរដ្ឋបាលជលផល**

**បានឃើញ និង យល់ព្រម**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០ ...

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៤៦ ប្រ.ក កសក

លិខិតចូល
ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ 2010

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហការប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញ អនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្ម ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ អនុក្រឹត្យលេខ ១៥អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## <u>ស ម្រេ ច</u>

**ប្រការ ១:** ប្រកាសនេះ សំដៅកំណត់នូវនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ ក្នុងការនាំចេញ នាំចូល ឆ្លងកាត់ ដឹកជញ្ជូនក្នុងព្រះរាជាណាចក្រកម្ពុជា នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ក្នុងគោលបំណង ទប់ស្កាត់ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ ដើម្បីការពារផលិតកម្មកសិកម្ម ជីវសាស្ត្រចម្រុះ និងសម្រួលសកម្មភាពពាណិជ្ជកម្មជាអន្តរជាតិ។

**ប្រការ ២:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើការនាំចេញ នាំចូល ឆ្លងកាត់ ដឹកជញ្ជូនក្នុងព្រះរាជាណាចក្រកម្ពុជា នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវសុំការត្រួតពិនិត្យតាមនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ និងត្រូវគោរពតាមគ្រប់វិធានភូតគាមអនាម័យ។

**ប្រការ ៣:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលនាំចូលនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យ លើទំនិញនាំចូលនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

- វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) និង/ឬ វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់នាំចេញបន្ត (Phytosanitary Certificate for Re Export) ដែលចេញដោយប្រទេសនាំចេញ និង/ឬ ប្រទេសនាំចេញបន្ត ( ជាគំរូច្បាប់ដើម)
- វិញ្ញាបនបត្រធូបទកម្ម (Fumigation Certificate) ក្នុងករណីដែលទំនិញបានធ្វើធូបទកម្ម មុនចូលមកដល់កម្ពុជា
- លិខិតអនុញ្ញាតនាំចូល (Import Licence for Agricultural Material) ដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្នុងករណីដែលទំនិញជាសម្ភារៈកសិកម្ម មាន ពូជដំណាំ ជី ថ្នាំកសិកម្ម ចំណីសត្វ ជាដើម)
- វិក្កយបត្រទំនិញ (Invoice) បញ្ជីវេចខ្ចប់ (Packing List) និងបញ្ជីផ្ទុកទំនិញ (Bill of lading)។

គំរូពាក្យសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូល និងកំណត់ហេតុស្តីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១ និង ២ នៃប្រកាសនេះ។

**ប្រការ ៤:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងនាំចូលនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលមានសក្តានុពលហានិភ័យខ្ពស់នៃសមាសភាពចង្រៃ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ៣ នៃប្រកាសនេះ ត្រូវបំពេញសំណុំបែបបទស្នើសុំជាមុននូវវិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (Import Certificate/Permit for Plant Quarantine Materials) នៅអគ្គនាយកដ្ឋានកសិកម្ម ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

- បញ្ជីឈ្មោះសមាសភាពចង្រៃមានវត្តមានរាតត្បាតក្នុងផលិតកម្ម និងការរក្សាទុកទំនិញដែលស្នើសុំក្នុងប្រទេសជាប្រភពដើមនៃទំនិញ
- បញ្ជីឈ្មោះសមាសភាពចង្រៃមានវត្តមានរាតត្បាតក្នុងផលិតកម្ម និងការរក្សាទុកទំនិញដែលស្នើសុំក្នុងប្រទេសដែលត្រូវដឹកជញ្ជូនឆ្លងកាត់ (ក្នុងករណីត្រូវឆ្លងកាត់ប្រទេសទី ២ មុនមកដល់កម្ពុជា)
- ឯកសារបច្ចេកទេសប្រព្រឹត្តកម្មនានា លើទំនិញដែលស្នើសុំ។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវឆ្លើយតបអំពីលទ្ធផលនៃការវិភាគហានិភ័យ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីទទួលបានសំណុំឯកសារខាងលើ។

នៅពេលនាំចូល រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលជាម្ចាស់ទំនិញ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចូលនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ , ដោយភ្ជាប់មកជាមួយនូវឯកសារ ដូចបានកំណត់ក្នុងប្រការ ៣ និងផ្តល់បន្ថែមនូវ:

- វិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (Import Certificate/Permit for Plant Quarantine Materials) ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្ម
- ឯកសារផ្សេងទៀតតាមការតម្រូវរបស់វិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (Import Certificate/ Permit for Plant Quarantine Materials) ដែលចេញដោយសមត្ថកិច្ចពាក់ព័ន្ធក្នុងប្រទេសនាំចេញ និង/ឬ នាំចេញបន្ត ។

គំរូពាក្យសុំនាំចូលទំនិញដែលជាកម្មវត្ថុត្រួតពិនិត្យភូតគាមអនាម័យ និង គំរូវិញ្ញាបនបត្រនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ៤ និង ៥ នៃប្រកាសនេះ។

**ប្រការ ៥:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងនាំចេញ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ នៅអគ្គនាយកដ្ឋានកសិកម្ម យ៉ាងតិចក្នុងរយៈពេល ១០ថ្ងៃ ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

- វិក្កយបត្រ (Invoice) និងបញ្ជីវេចខ្ចប់ (Packing list)

- វិញ្ញាបនបត្រធូបទកម្ម (Fumigation certificate) (ប្រសិនបើមាន)
- លិខិតអនុញ្ញាតនាំចូល (Import Permit issued by the importing country) (ប្រសិនបើមាន)
- បណ្តាលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល (ប្រសិនបើមាន)
- វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសជាប្រភពដើមនៃទំនិញ (ក្នុងករណីសុំនាំចេញបន្ត)

គំរូសំណុំពាក្យសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ កំណត់ហេតុស្តីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញ វិញ្ញាបនបត្រភូតគាមអនាម័យលើទំនិញនាំចេញ និង វិញ្ញាបនបត្រភូតគាមអនាម័យលើទំនិញសម្រាប់នាំចេញបន្ត ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ៦, ៧, ៨ និង ៩ នៃប្រកាសនេះ។

**ប្រការ ៦:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងដឹកជញ្ជូនឆ្លងកាត់នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញដឹកជញ្ជូនឆ្លងកាត់នៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យច្រកទ្វារនាំចូល ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម :

- វិក្កយបត្រទំនិញ (Invoice) បញ្ជីវេចខ្ចប់ (Packing List) និងបញ្ជីផ្ទុកទំនិញ (Lading bill)
- វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) និង/ឬ វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់នាំចេញបន្ត (Phytosanitary Certificate for Re Export) ដែលចេញដោយប្រទេសនាំចេញ និង/ឬ ប្រទេសនាំចេញបន្ត (ជាគំរូច្បាប់ដើម)
- វិញ្ញាបនបត្រធូបទកម្ម (Fumigation Certificate) ក្នុងករណីដែលទំនិញបានធ្វើធូបទកម្ម មុនចូលមកដល់កម្ពុជា

ម្ចាស់ទំនិញត្រូវបង្ហាញសំណុំបែបបទខាងលើ នៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យច្រកទ្វារចេញ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុស្តីពីការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់ ដែលបានទទួលពីច្រកទ្វារចូល។

គំរូសំណុំឯកសារសម្រាប់ស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់ និងកំណត់ហេតុស្តីពីលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញឆ្លងកាត់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ ១០ និង ១១ នៃប្រកាសនេះ។

**ប្រការ ៧:** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងដឹកជញ្ជូន ចេញ ចូល ឬ ឆ្លងកាត់ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យពីតំបន់ណាមួយនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសជាតំបន់រាលដាលឆ្លងសមាសភាពចង្រៃភូតគាមអនាម័យ ឬសមាសភាពចង្រៃបង្កគ្រោះថ្នាក់

ត្រូវសុំការត្រួតពិនិត្យភូតគាមអនាម័យ ទៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យបណ្ដោះអាសន្នណាមួយដែលនៅជិតបំផុត ដោយត្រូវគោរពតាមវិធានភូតគាមអនាម័យ ដូចខាងក្រោម៖

ក. ផ្អាកទាំងស្រុងចំពោះការដឹកជញ្ជូន ឬ យកចេញ ឬ ឆ្លងកាត់ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ជាជម្រកភាគត្បាតផ្ទាល់របស់សមាសភាពចង្រៃ ដែលកំពុងរាលដាលឆ្លង រហូតដល់សមត្ថកិច្ចភូតគាមអនាម័យធ្វើការកំចាត់បានទាំងស្រុង។

ខ. ការដឹកជញ្ជូន ឬ យកចេញ ចូល ឬ ឆ្លងកាត់ នូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ មិនមែនជាជម្រកភាគត្បាតផ្ទាល់របស់សមាសភាពចង្រៃដែលកំពុងរាលដាលឆ្លង អាចធ្វើទៅបានក្រោយពីបានត្រួតពិនិត្យ និងទទួលការអនុញ្ញាតពីសមត្ថកិច្ចភូតគាមអនាម័យ។

